**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 18 PR-25/EoJ 27 March 2025

## Japan Provides US$199,454 for Empowerment of Environmental Education in Kindergartens

The Government of Japan will provide US$199,454 for a recipient organizations under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representative of recipient, to carry out the following projects:

'Empowerment of Infants and Their Parents in Cambodia through Environmental Education' (US$199,454)
Recipient: Nature Center Risen (NCR)

In this project, Nature Center Risen will implement environmental education for young children and their parents in some kindergartens in Cambodia to spread a succeeded educational curriculum from some modeled kindergartens in Sihanoukville. They will improve school facilities and create educational materials related to environmental education in collaboration with the Ministry of Education, Youth, and Sports (MoEYS) of Cambodia and the Provincial Offices of Education, Youth, and Sports (PoEYS). Through this project, it is aimed to extend environmental education to all the local kindergartens from these model institutions.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$56 million for over 160 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website:* *http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសពត៌មាន**

លេខ. 25 PR-24/EoJ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥

## ជប៉ុនផ្តល់ថវិកា ១៩៩,៤៥៤ ដុល្លារអាមេរិក សម្រាប់ការលើកកម្ពស់ការអប់រំបរិស្ថានក្នុងសាលាមត្តេយ្យសិក្សា

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **១៩៩,៤៥៤ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយមួយ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយ សម្រាប់អនុវត្តគម្រោងខាងក្រោម៖

**"គម្រោងលើកកម្ពស់ការអប់រំបរិស្ថានដល់កុមារតូចនិងអ្នកអាណាព្យាបាលទូទាំងប្រទេស តាមរយៈសាលាមត្តេយ្យសិក្សាគំរូក្នុងប្រទេសកម្ពុជា" (ថវិកាចំនួន ១៩៩,៤៥៤ ដុល្លារអាមេរិក)**
**ស្ថាប័នទទួលជំនួយ៖ អង្គការ Nature Center Risen (NCR)**

នៅក្នុងគម្រោងនេះ អង្គការ Nature Center Risen នឹងអនុវត្តការអប់រំបរិស្ថានដល់កុមារតូចនិងអាណាព្យាបាល ក្នុងសាលាមត្តេយ្យមួយចំនួននៅកម្ពុជាដើម្បីផ្សព្វផ្សាយកម្មវិធីសិក្សាអប់រំដែលទទួលបានជោគជ័យពីសាលាមត្តេយ្យគំរូមួយចំនួនក្នុងខេត្តព្រះសីហនុ។ អង្គការនឹងធ្វើឲ្យប្រសើរឡើងនូវបរិក្ខារសាលារៀន និងបង្កើតសម្ភារសិក្សាដែលទាក់ទងនឹងការអប់រំបរិស្ថានដោយមានការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជានិងការិយាល័យអប់រំ យុវជន និងកីឡាតាមបណ្តាខេត្ត។ គម្រោងនេះមានគោលបំណងពង្រីកការអប់រំបរិស្ថានដល់មត្តេយ្យសិក្សាក្នុងតំបន់ទាំងអស់ពីស្ថាប័នគំរូទាំងនេះ។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពី

ឆ្នាំ២០០២ មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៥៦លាន ដុល្លារអាមេរិក ដល់គម្រោងចំនួន ១៦០ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---


ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១

អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp

គេហទំព័រ៖ *http://www.kh.emb-japan.go.jp*

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥

នៅថ្ងៃទី២៧ ខែមីនា កិច្ចសន្យាផ្តល់ជំនួយរបស់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចុះហត្ថលេខា។ ដោយសារកាលៈទេសៈរបស់ស្ថានទូតជប៉ុន និងស្ថាប័នទទួលជំនួយ ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ និងឯកសារពាក់ព័ន្ធដាច់ដោយឡែកពីគ្នា។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលហៅថា "អ៊ិនរ៉េន" បានចាប់ផ្តើមតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្តល់ជំនួយជាង ១៦០គម្រោង នៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ ហើយគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

សេចក្តីសង្ខេបអំពីគម្រោងដែលចុះហត្ថលេខានាថ្ងៃនេះមានដូចតទៅ៖
ស្ថាប័នទទួលជំនួយ៖ អង្គការ Nature Center Risen (NCR)
"គម្រោងលើកកម្ពស់ការអប់រំបរិស្ថានដល់កុមារតូចនិងអ្នកអាណាព្យាបាលទូទាំងប្រទេស តាមរយៈសាលាមត្តេយ្យសិក្សាគំរូក្នុងប្រទេសកម្ពុជា"

ខ្ញុំសូមជម្រាបជូនដោយសង្ខេបនូវគម្រោងដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ៖

រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាប្រមាណ ២០០ ០០០ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការ Nature Center Risen។
អង្គការ NCR បាននឹងអនុវត្តការអប់រំបរិស្ថានសម្រាប់កុមារមត្តេយ្យដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងគម្រោងនេះ បន្ថែមពីលើការអនុវត្តការអប់រំបរិស្ថាននៅតាមសាលាដែលបានជ្រើសរើសក្នុងខេត្តព្រះសីហនុឲ្យទៅជាកម្មវិធីសិក្សាគំរូ អង្គការនឹងផ្សព្វផ្សាយការ

អប់រំបរិស្ថានរបស់សាលារៀនក្នុងខេត្តព្រះសីហនុ ដល់សាលារៀននៅបណ្ដាខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា។ ខ្ញុំទទួលស្គាល់ថាតម្រូវការនៃការអប់រំបរិស្ថានកាន់តែចាំបាច់ ដោយកម្ពុជាដែលជាប្រទេសសំបូរទៅដោយសម្បត្តិធម្មជាតិ កំពុងជួបប្រទះបញ្ហាបរិស្ថានកាន់តែធ្ងន់ធ្ងរទៅៗស្របនឹងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ តាមរយៈគម្រោងនេះដែលជំរុញការអប់រំបរិស្ថានដល់កុមារមត្តេយ្យនិងអាណាព្យាបាលរបស់ពួកគេនៅទូទាំងប្រទេសកម្ពុជា ខ្ញុំសង្ឃឹមថាបរិយាកាសរស់នៅនឹងត្រូវបានកែលម្អដោយមានការផ្លាស់ប្ដូរសកម្មភាពរស់នៅប្រចាំថ្ងៃដោយសារការលើកកម្ពស់ស្មារតីស្រលាញ់ចំពោះបរិស្ថាន។

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន។ រដ្ឋាភិបាលជប៉ុន នឹងបន្តសហការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជប៉ុននានា និងគាំទ្រការងាររបស់ពួកគេក្នុងការដោះស្រាយបញ្ហានានា។

ស្ថានទូតជប៉ុន

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

អ៊ូអិណុ អាត់ស៊ូស៊ី